**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាម**
**បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំលើកទី១២របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់បណ្តាញសារព័ត៌មានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យបានជ្រាបថា គ.ជ.អ.ប នឹងរៀបចំកិច្ចប្រជុំលើកទី១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**។

កិច្ចប្រជុំនេះមានរបៀបវារៈដូចខាងក្រោមៈ

១.ការពិភាក្សា និងអនុម័តលើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំលើកទី១១ របស់ គ.ជ.អ.ប។

២.ការពិភាក្សា និងអនុម័តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធទៅឲ្យរដ្ឋបាលក្រុង ស្រុក។

៣.ការពិភាក្សា និងអនុម័តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤.ការពិភាក្សា និងអនុម័តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតសាលាជាតិរដ្ឋបាល មូលដ្ឋាន។

៥.បញ្ហាផ្សេងៗៈ

- បញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។
- ការបែងចែកការទទួលខុសត្រូវរបស់ថ្នាក់រដ្ឋបាលនានាលើមុខងារមួយចំនួននៃវិស័យអាទិភាពមួយចំនួន។

**ទីកន្លែង:** នៅសាលប្រជុំក្រសួងមហាផ្ទៃ (អគារ A) អាសយដ្ឋានៈ មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ
**ពេលវេលា:** នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ចាប់ពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ១២:០០ថ្ងៃត្រង់

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីដែលជាអ្នកសារព័ត៌មានទាំងអស់ អញ្ជើញចូលរួមយកព័ត៌មានតាមកាលបរិច្ឆេទ និងពេលវេលាខាងលើកុំបីខាន។

*ព័ត៌មានបន្ថែមសូមទំនាក់ទំនងលេខាធិការដ្ឋាន គ.ជ.អ.ប តាមរយៈលេខទូរស័ព្ទ ០៧៨ ៥៧ ៥៧ ៧៥; ០១២ ៧៩ ២៣ ៧២ ; E-mail: tharith@ncdd.gov.kh ; sochan@ncdd.gov.kh; Website: www.ncdd.gov.kh។*